# អ្នកគង្វាលល្អ

ដោយ អែរិន សាន់ដឺសុន

ថ្ងៃមួយព្រះយេស៊ូវគ្រីស្ទបានប្រាប់រឿងមួយ ( ឬ រឿងប្រៀបធៀប ) អំពីអ្នកគង្វាលម្នាក់ដែលស្រឡាញ់ចៀមរបស់គាត់ខ្លាំងណាស់ ដែលគាត់នឹងប្រគល់សូម្បីតែជីវិតគាត់ដើម្បីការពារពួកវា ។ យើងគឺដូចជាចៀមនៅក្នុងរឿងនោះដែរ ។ ហើយអ្នកគង្វាលគឺដូចជាព្រះអង្គសង្គ្រោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ ។ ពេលខ្លះទ្រង់ត្រូវបានហៅថាជាអ្នកគង្វាលដ៏ល្អ ។

ព្រះយេស៊ូវបានបង្ហាញសេចក្ដីស្រឡាញ់របស់ទ្រង់ នៅពេលឪពុកម្ដាយមួយចំនួនបាននាំកូនៗរបស់ពួកគេមកមើលទ្រង់ ។ ទ្រង់មានព្រះបន្ទូលថា « **ទុកឲ្យ** កូនក្មេងមកឯខ្ញុំចុះ **កុំឃាត់វាឡើយ** ដ្បិតនគរព្រះមានសុទ្ធតែមនុស្ស ដូចវារាល់គ្នាដែរ » ( លូកា ១៨:១៦ ) ។ បន្ទាប់មក ទ្រង់បាននាំពួកគេមកក្នុងរង្វង់ព្រះហស្តទ្រង់ ហើយប្រទានពរដល់ពួកគេ ។

សូមបិទភ្នែករបស់អ្នក ហើយស្រមៃថា ព្រះអង្គសង្គ្រោះកំពុងកាន់ដៃអ្នកនៅក្នុងព្រះហស្តទ្រង់ ហើយកំពុងប្រទានពរដល់អ្នក ។ អ្នកអាចទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ទ្រង់ ពេលអ្នករៀន ឬ គិតអំពីទ្រង់ ។ ព្រះវិញ្ញាណបរិសុទ្ធជួយអ្នកឲ្យទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់ពីអ្នកគង្វាលដ៏ល្អ គឺព្រះយេស៊ូវគ្រីស្ទ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា ។*



## រៀនបន្ថែមទៀត

***ទុកឲ្យ*** — អនុញ្ញាត

***កុំឃាត់វាឡើយ*** — កុំបញ្ឈប់ពួកគេឡើយ

## ការនិយាយក្នុងក្រុមគ្រួសារ

សូមអាន យ៉ូហាន ១០:១–៥, ១១–១៦ ។ បន្ទាប់មក សូមឆ្លើយតបមួយអំពីរបៀបដែលព្រះយេស៊ូវគឺដូចជាអ្នកគង្វាល ហើយប្រាប់អំពីពេលវេលាទាំងឡាយដែលអ្នកមានអារម្មណ៍ពីសេចក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ ។

***ចម្រៀង ៖*** “I Think When I Read That Sweet Story” ( Children’s Songbook, 56 )

***ខគម្ពីរ ៖*** លូកា ១៨:១៥–១៧; យ៉ូហាន ១០:១–៥, ១១–១៦ ។

***វីដេអូ ៖*** “Suffer the Little Children to Come Unto Me” និង “Jesus Teaches that We Must Become as Little Children” ( Biblevideos.org )

រចនារូបភាពដោយ ហ្វីលីស លូច ( ខាងឆ្វេង ) និង ប៉ុល ម៉ាន់ ( ខាងស្ដាំ )



## អ្នកគង្វាលល្អ

សូមកាត់យករូបភាពនេះ ។ បត់វាធ្វើជាផ្លិតទៅតាមបន្ទាត់ពណ៌ស ។ បន្ទាប់មកបើកវាមកវិញ ហើយមើលវាពីខាងស្ដាំ និង ពីខាងឆ្វេង ។ តើអ្នកមានអារម្មណ៍យ៉ាងណា ចំពោះសេចក្ដីស្រឡាញ់របស់អ្នកគង្វាលដ៏ល្អរបស់យើង ?

## ពណ៌មានពីព្រះគម្ពីរ

សូមរកមើលពាក្យ « ដំណឹងល្អ » នៅក្នុងសេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ សម្រាប់តារាងមួយដែលប្រាប់អំពីព្រឹត្តិការណ៍ ឬ ការបង្រៀននីមួយៗ ។ មានតែគម្ពីរយ៉ូហានប៉ុណ្ណោះដែលប្រាប់អំពីអ្នកគង្វាលល្អ ។ គម្ពីរបី — ម៉ាថាយ ម៉ាកុស និង លូកា — ប្រាប់អំពីព្រះយេស៊ូវប្រទានពរដល់កូនក្មេង ។